# កិច្ចការមួយដែលរួមចំណែកធ្វើឱ្យតុលាការខ្មែរក្រហមអាចទទួលយកបាន

តាមគោលការណ៍ច្បាប់ព្រហ្មទណ្ឌក្នុងស្រុកក៏ដូចជាគោលការណ៍ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ផ្នែកមួយដ៏សំខាន់ដែលនឹងធ្វើឲ្យដំណើរការកាត់សេចក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យអាចទទួលយកបាន គឺសិទ្ធិរបស់ចុងចោទឬជនជាប់ចោទដែលច្បាប់បានកំណត់ជូន ត្រូវបានធានាឲ្យបានល្អឥតខ្ចោះតាមដែលអាចធ្វើទៅបាន ។ មជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើកិច្ចការនេះតាមរយៈការរៀបចំឲ្យមានវគ្គហ្វឹកហ្វឺនច្បាប់ ។

នេះជាលើកទី៤នៅក្នុងឆ្នាំ២០០៥ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំឲ្យមានវគ្គហ្វឹកហ្វឺនច្បាប់ដែលផ្តោតការយកចិត្តទុកដាក់ទៅលើប្រធានបទដើម្បីតម្រូវតាមគោលការណ៍ច្បាប់ព្រហ្មទណ្ឌដូចបានបង្ហាញជូន ។ ក្នុងឆ្នាំ២០០៥នេះ វគ្គហ្វឹកហ្វឺនច្បាប់បានបញ្ចប់ជាស្ថាពរកាលពីថ្ងៃសុក្រទី៣០ ខែកញ្ញា ក្រោមការជួយឧបត្ថម្ភពីការិយាល័យទទួលបន្ទុកការងារសិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យនៃក្រសួងការបរទេសសហរដ្ឋអាមេរិក តាមរយៈជំនួយអភិវឌ្ឍអន្តរជាតិរបស់សហរដ្ឋអាមេរិក រដ្ឋាភិបាលហូល្លង់ និងរដ្ឋាភិបាលស៊ុយអែដ ។

វគ្គហ្វឹកហ្វឺននេះមានសិក្ខាកាមចូលរួមយ៉ាងហោចណាស់ចំនួន៨៤នាក់មកពីអង្គការក្រៅរដ្ឋាភិបាលនានា អ្នកកាសែត មេធាវី និស្សិតច្បាប់ និស្សិតមេធាវី ព្រមទាំងប្រជាពលរដ្ឋសាមញ្ញដែលធ្លាប់រងគ្រោះក្នុងរបបវាលពិឃាដមកពីតាមបណ្តាខេត្តមួយចំនួនដូចជា ខេត្តព្រៃវែង កំពង់ចាម កំពត កណ្តាល ពោធិ៍សាត់ កំពង់ធំ និងស្វាយរៀង ។

ផ្អែកលើគោលការណ៍ច្បាប់ព្រហ្មទណ្ឌខាងលើ វគ្គហ្វឹកហ្វឺនច្បាប់ដែលមជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំឡើងដោយប្រយ័ត្នប្រយែងបានផ្តោតការយកចិត្តទុកដាក់ទៅលើ «ការការពារចុងចោទនៅក្នុងបរិបទយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិជាទូទៅ និងនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ដែលហៅកាត់ថា តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម) ។

ពិស្តារជាងនេះ សិក្ខាកាមបានយល់ជ្រួតជ្រាបថែមទៀតទាក់ទិននៅនឹងៈ សេចក្តីផ្តើមទូទៅអំពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម, សិទ្ធិរបស់ចុងចោទ, តួនាទីរបស់មេធាវីចុងចោទ, ការលំបាកចម្បងៗមេធាវីចុងចោទអាចប្រឈមមុខ, សិទ្ធិនិងកាតព្វកិច្ចរបស់មេធាវីចុងចោទនៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម, ប្រភេទផ្សេងៗនៃការការពារក្តី, បណ្តឹងស្នើសុំរបស់មេធាវីចុងចោទមុនពេលបើកសវនាការ, និង ការធ្វើទឡ្ហីករណ៍ចុងក្រោយរបស់មេធាវីចុងចោទនៅពេលបើកសវនាការ ។

ប្រធានបទទាំងប៉ុន្មានដែលរៀបរាប់ខាងលើត្រូវបានបង្ហាត់បង្រៀនដោយគ្រូឧទ្ទេសនាមខ្មែរពីររូបនិងបរទេសប្រាំបួនរូប ដែលមានបទពិសោធន៍ខ្ពស់ទាក់ទិននឹងការការពារក្តីចុងចោទពីបទឧក្រិដ្ឋកម្មនៅតុលាការក្នុងស្រុករបស់ខ្លួន ដូចជា នៅតុលាការប្រទេសអាមេរិក ហូល្លង់ អង់គ្លេស បារាំង និងនៅតុលាការព្រហ្មទណ្ឌអន្តរជាតិនានា ដូចជាតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (អាយស៊ីធីវ៉ាយ) រ៉ាន់ដា (អាយស៊ីធីអ័រ) តុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូន និងតុលាការសិទ្ធិមនុស្សសម្រាប់សហគមន៍អឺរ៉ុបជាដើម ។

នៅថ្ងៃបញ្ចប់វគ្គហ្វឹកហ្វឺន សិក្ខាកាមទាំងអស់តម្រូវឲ្យបំពេញទម្រង់វាយតម្លៃម្នាក់មួយសន្លឹក ដែលតាមរយៈនេះមានសិក្ខាកាមខ្លះសរសេរថា «ខ្ញុំចូលចិត្តមេរៀនអំពីតួនាទីរបស់មេធាវីចុងចោទនៅចំពោះមុខតុលាការកាត់សេចក្តីមេដឹកនាំខ្មែរក្រហម» ខ្លះទៀតសរសេរថា «ខ្ញុំចូលចិត្តមេរៀនអំពីសិទ្ធិរបស់ចុងចោទ» «ខ្ញុំចូលចិត្តវគ្គហ្វឹកហ្វឺននេះពីព្រោះថាធ្វើឲ្យខ្ញុំយល់ជ្រួតជ្រាបអំពីច្បាប់ដែលនឹងត្រូវយកទៅអនុវត្តនៅក្នុងតុលាការខ្មែរក្រហម និងយល់ជ្រួតជ្រាបអំពីមាត្រា១៤និង១៥នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ» «ការបង្ហាត់បង្ហាញអំពីសិទ្ធិចុងចោទនិងតួនាទីរបស់មេធាវីចុងចោទ ជួយឲ្យប្រជាពលរដ្ឋយល់ដឹងអំពីដំណើរការតុលាការ និងកាត់បន្ថយការគាបសង្កត់ផ្នែកសង្គមទៅលើមេធាវីចុងចោទ» ។ល។

**អ៊ាន់ថាន់ ពៅ ដារ៉ា**